ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីប្រកាសព័ត៌មាន

## "កម្ពុជា និងថៃ ជឿជាក់ថា ទំនាក់ទំនងគ្រប់វិស័យនឹងត្រូវពង្រីកបន្ថែមទៀត"

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២៣ - **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង **ឯកឧត្តម ឆឺតកៀត អាត់ថាកន** (Cherdkiat Atthakor) ឯកអគ្គរាជទូតថ្មី នៃព្រះរាជាណាចក្រថៃ ប្រចាំកម្ពុជា បានសម្តែងនូវការពេញចិត្តយ៉ាងជ្រាលជ្រៅចំពោះទំនាក់ទំនងទ្វេភាគីដ៏រឹងមាំ និងមានជំនឿថា កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ នឹងត្រូវពង្រីកបន្ថែមទៀត ក្នុងឱកាសដែល ឯកឧត្តម ឯកអគ្គរាជទូត ចូលជួបសម្តែងការគួរសមជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣ នាទីស្តីការក្រសួង។

ភាគីទាំងពីរបានពិភាក្សាអំពីភាពជាដៃគូទ្វេភាគី ក្នុងវិស័យមួយចំនួន ដូចជា ពាណិជ្ជកម្ម និងការវិនិយោគ ការងារ អប់រំ ការដោះមីន ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ រួមទាំង ច្រកព្រំដែនអន្តរជាតិផងដែរ។ ភាគីទាំងពីរបានផ្តល់សារៈសំខាន់ចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នា សំដៅសម្រេចឱ្យបាននូវគោលដៅពាណិជ្ជកម្មទ្វេភាគី ក្នុងទំហំទឹកប្រាក់ ១៥ ពាន់លាន ដុល្លារអាមេរិក នៅឆ្នាំ ២០២៥ និងប្រតិបត្តិការបោសសម្អាតមីននៅតាមបណ្តោយព្រំដែន ដោយពុំចាំបាច់រង់ចាំការបញ្ចប់ការងារកំណត់ព្រំដែន នោះឡើយ។ អាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ កំពុងរៀបចំឯកសារស្តីពី កម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់រយៈពេល ៣ ឆ្នាំ បន្ទាប់ (២០២៣-២០២៥)។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើប្រទេសថៃ បន្តផ្តល់ការយកចិត្តទុកដាក់ចំពោះពលករកម្ពុជា និងបន្តផ្តល់អាហារូបករណ៍ ជូនដល់និស្សិតកម្ពុជា។ ក្នុងនាមជាអតីតអ្នកការទូតថៃ នៅទីក្រុងភ្នំពេញ កាលពី៣០ឆ្នាំមុន ឯកឧត្តមឯកអគ្គរាជទូត **អាត់ថាកន** បានចំណាប់អារម្មណ៍ និងពិនិត្យឃើញដោយផ្ទាល់នូវការរីកចម្រើនយ៉ាងឆាប់រហ័ស នៅកម្ពុជា។ ជាងនេះទៅទៀត ឯកឧត្តមឯកអគ្គរាជទូត ក៏បានជម្រាបជូនអំពីការត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ឧបនាយករដ្ឋមន្ត្រីនៅប្រទេសថៃ ដែលគ្រោងនឹងធ្វើឡើងនៅចុងខែនេះ ផងដែរ ។

ឯកឧត្តមឯកអគ្គរាជទូតថ្មី បានអបអរសាទរកម្ពុជាចំពោះសមិទ្ធិផលនានាដែលសម្រេចបានក្នុងឋានៈជាប្រធានអាស៊ាន និងបានកោតសរសើរចំពោះតួនាទីដ៏សំខាន់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងឋានៈជាប្រេសិតពិសេសរបស់ប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា កាលពីឆ្នាំមុន។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានសាទរប្រទេសថៃ ដែលបានធ្វើជាប្រធាន APEC ប្រកបដោយជោគជ័យ នៅឆ្នាំ ២០២២ ផងដែរ៕

អាសយដ្ឋានៈ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh